ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១៤១ / គ.ជ.ប
/ ០៧

គោរពជូន
ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ** : សំណើជួយអន្តរាគមន៍ទៅគ្រប់ប្រធានក្រុមហ៊ុនសន្តិសុខឯកជនទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យបុគ្គលិកសន្តិសុខបានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អាទិត្យ ទី ០១ ខែ មេសា ឆ្នាំ ២០០៧ ។

**យោង** : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧ ។

តបតាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជំរាបឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជ្រាបថា នៅថ្ងៃ អាទិត្យ ទី ០១ ខែ មេសា ឆ្នាំ ២០០៧ ខាងមុខនេះ ជាកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ។

អាស្រ័យហេតុនេះដើម្បីសម្រួលដល់បុគ្គលិកសន្តិសុខឯកជនទាំងអស់ ដែលបានចុះឈ្មោះបោះឆ្នោតហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីជួយអន្តរាគមន៍ទៅគ្រប់ប្រធានក្រុមហ៊ុនសន្តិសុខឯកជនទាំងអស់ដើម្បីឱ្យបុគ្គលិកបានទៅបោះឆ្នោតតាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ ២០០៧
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ទឹម ស៊ុន្ទី

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋាននគរបាលជាតិ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
- ឯកសារ កាលប្បវត្តិ